**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ.[illegible]

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ[illegible] ឆ្នាំ ២០០៧

# ប្រកាសរួមអន្តរក្រសួង

## ស្តីពី

## ការអនុវត្តន៍អនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផលនិងសេវាកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន

ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥-២៣) ៤២៦ ០៣៤ - ៤២៦ ៨៤១ ទូរស័ព្ទ (៨៥៥-២៣) ៧២២ ៩៣៣
MINISTRY OF HEALTH N° 151-153 AVENUE KAMPUCHEA KROM PHNOM PENH, CAMBODIA,PHONE/FAX (855-23) 426 034 – 426 841 Tel: (855-23) 722 933

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ

**សម្រេច**

**ប្រការ ១.-**

ប្រកាសរួមនេះមានគោលដៅអនុវត្តន៍តាមមាត្រា ១៧ និង ២២ នៃអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ។ ការទទួលខុសត្រូវក្នុងការអនុវត្តន៍អោយមានប្រសិទ្ធភាពនូវប្រកាសរួមនេះនឹងត្រូវអនុវត្តស្របទៅតាមបទប្បញ្ញត្តិនៃអនុក្រឹត្យ ។

**ប្រការ ២.-**

ក្រសួងសុខាភិបាលត្រូវធានានូវ ÷

ក- ការផ្សព្វផ្សាយ និងការប្រើប្រាស់សមស្របនូវផលិតផលចិញ្ចឹមទារក និងកុមារ ស្របតាមបទប្បញ្ញត្តិនៃ អនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ជាពិសេសត្រូវយកចិត្តទុកដាក់លើអាយុសមស្របដែលត្រូវប្រើប្រាស់ផលិតផលទាំងនោះ ។

ខ- ការផ្តល់យោបល់លើខ្លឹមសារនៃស្លាកផលិតផល ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ដល់ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ។

គ- ការប្រើប្រាស់សមស្របនូវផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ នៅក្នុងប្រព័ន្ធគាំពារសុខភាព ទាំងក្នុងគ្រឹះស្ថានសុខាភិបាលឯកជន និងសាធារណៈក្នុងករណីចាំបាច់ ។

ឃ- ការហាមឃាត់នូវរាល់ការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារគ្រប់រូបភាព នៅក្នុងប្រព័ន្ធគាំពារសុខភាព ទាំងក្នុងគ្រឹះស្ថានឯកជន និងគ្រឹះស្ថានសាធារណៈ ដែលរាប់បញ្ចូលទាំងការចែកចាយដោយឥតគិតថ្លៃ ឬដោយតំលៃថោក ចំពោះការឧបត្ថម្ភផ្គត់ផ្គង់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ។

ង- ការហាមឃាត់ឯកសារ និងព័ត៌មានអប់រំដែលមានគោលបំណងចែកជូន អ្នកប្រកបអាជីពសុខាភិបាល លើកលែងតែព័ត៌មានវិទ្យាសាស្ត្រ និងការពិត ហើយមិនប៉ះពាល់ដល់ការបំបៅកូនដោយទឹកដោះម្តាយ ឬលើកកំពស់ការប្រើប្រាស់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ។ ✓ ✓

ច- រាល់ឯកសារ និងព័ត៌មានអប់រំដែលមានគោលបំណងចែកជូនសាធារណជន ត្រូវអនុលោមទៅតាមមាត្រា ៦. ៧ និង ៨ នៃអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ។

ឆ- ការផ្សព្វផ្សាយផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារដែលនឹងត្រូវផ្តល់ជូនក្នុងករណីពិសេស កាលណាក្រសួងបានកំណត់សំរេចថា ផលប៉ះពាល់នៃខ្លឹមសារផ្សព្វផ្សាយនឹងជំរុញឱ្យមានការបំបៅកូនដោយដោះម្តាយ និងបញ្ជាក់ច្បាស់ពីហានិភ័យនៃការប្រើផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ។ រាល់ខ្លឹមសារផ្សព្វផ្សាយត្រូវតែគោរពតាមល័ក្ខខ័ណ្ឌទាំងឡាយដូចខាងក្រោមនេះ ÷

- រាល់ការបោះពុម្ពផ្សាយតាមផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងគំនូរ ឬលិខិតប្រកាស និងការផ្សាយពាណិជ្ជកម្មជាសម្លេង ឬសោតទស្សន៍ ត្រូវតែប្រើយ៉ាងហោចណាស់ហាសិបភាគរយនៃខ្លឹមសារ "**ទារកដែលមិនបានទទួលទឹកដោះម្តាយប្រឈមមុខនឹងជម្ងឺរាករូស រលាកផ្លូវដង្ហើម និងជម្ងឺផ្សេងៗ ដែលមានអាត្រាស្លាប់ខ្ពស់។ ការបំបៅដោះម្តាយតែមួយមុខគត់ ពីកើតរហូតដល់អាយុប្រាំមួយខែ អាចសង្គ្រោះជីវិតទារកបន្ថែមបានប្រហែល ១.៣ លាននាក់ និងបានលើកកំពស់សុខភាពទារក និងកុមារច្រើនលាននាក់ផ្សេងទៀតជារៀងរាល់ឆ្នាំ**" ។

ជ- កុំឱ្យមានទំនាស់ផលប្រយោជន៍ នៅពេលផ្តល់ការអនុញ្ញាតដល់កិច្ចប្រជុំ សិក្ខាសាលា ការអប់រំបន្ត សន្និសីទ ឬព្រឹត្តិការណ៍ទាំងឡាយរបស់ផលិតករ ឬអ្នកចែកចាយ តាមខ្លឹមសារមាត្រា ១៤ នៃអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ដោយមានការផ្តល់យោបល់ជាលាយល័ក្ខណ៍អក្សរពីក្រុមការងារបច្ចេកទេសចិញ្ចឹមទារក និងកុមារ មុននឹងផ្តល់ការអនុញ្ញាតនេះ។ ប្រសិនបើមិនគោរពតាមល័ក្ខខ័ណ្ឌ កំណត់របស់ក្រសួងសុខាភិបាល កិច្ចប្រជុំ ឬព្រឹត្តិការណ៍ទាំងនោះ មិនត្រូវបានអនុញ្ញាតឱ្យប្រារព្ធឡើង ដើម្បីផ្សព្វផ្សាយផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារឡើយ ។

ឈ- ការផ្សព្វផ្សាយអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ និងប្រកាសរួមនេះក្នុងទម្រង់ឯកសារដែលងាយស្រួលប្រើសំរាប់អ្នករៀបចំគោលនយោបាយ អ្នកប្រកបអាជីពសុខាភិបាល និងសាធារណជន ។

**ប្រការ ៣.-**

ក្រសួងពាណិជ្ជកម្មត្រូវធានា ÷

ក- ត្រួតពិនិត្យស្លាកផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារដែលនាំចូល បានគោរពតាមមាត្រា ៩. ១០. ១១ និង ១២ នៃអនុក្រឹត្យ ។ ក្នុងករណីនេះក្រសួងពាណិជ្ជកម្ម គួរស្នើសុំយោបល់ពីក្រសួងសុខាភិបាលបើមានការចាំបាច់ ។

ខ- ត្រួតពិនិត្យស្លាកផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ក្នុងស្រុកបានគោរពតាមមាត្រា ៩. ១០. ១១ និង ១២ នៃអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ តាមរយៈសកម្មភាពត្រួតពិនិត្យ និងការអនុវត្តន៍ច្បាប់ឱ្យបានត្រឹមត្រូវ និងដោយមានកិច្ចសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលផង ។

គ- រាល់ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយក្នុងរូបភាពផ្សេងៗទៀតនូវផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ទោះជាដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី ចំពោះសាធារណជន ត្រូវអនុលោមតាមមាត្រា ១៣ នៃអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ តាមរយៈសកម្មភាពត្រួតពិនិត្យ និងការអនុវត្តន៍ឱ្យបានត្រឹមត្រូវ ។ ៥ ៥

**ប្រការ ៤.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវធានា ÷

ផ្តល់ស្លាកនៃផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារក្នុងស្រុក ដោយគោរពតាមមាត្រា ៩, ១០, ១១ និង ១២ នៃអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។ ក្នុងករណីនេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គួរស្នើសុំយោបល់ជាលាយលក្ខណ៍អក្សរ ពីក្រសួងសុខាភិបាល មុននឹងផ្តល់ការឯកភាពលើស្លាកណាមួយនៃផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារណាមួយក្នុងករណីចាំបាច់។

**ប្រការ ៥.-**

ក្រសួងព័ត៌មានត្រូវបញ្ជាប់ ÷

រាល់ការឃោសនាពាណិជ្ជកម្មអំពីផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ក្នុងករណីដែលក្រសួង ឬស្ថាប័នពាក់ព័ន្ធធ្វើលិខិតជាលាយលក្ខណ៍អក្សរជូនទៅក្រសួងព័ត៌មាន ដើម្បីស្នើសុំធ្វើកិច្ចសហការ ចាត់វិធានការជាបន្ទាន់ ដោយបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណស្ថានីយ៍ វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ឬព្រឹត្តិប័ត្រណាមួយដែលកំពុងផ្សព្វផ្សាយឃោសនាពាណិជ្ជកម្មអំពីផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារដែលបំពានលើល័ក្ខខ័ណ្ឌកំណត់នៃអនុក្រឹត្យ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។

**ប្រការ ៦.-**

ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីការចេញប្រកាសរួមនេះ ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបង្កើតរចនាសម្ព័ន្ធ និងនីតិវិធីចាំបាច់ដើម្បីទទួលស៊ើបអង្កេត និងចាត់វិធានការ នៅពេលមានរបាយការណ៍ ពីការបំពានអនុក្រឹត្យដែលអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និង សាធារណជនបានដាក់ជូនទៅក្រុមប្រឹក្សាតាមដានដូចមានចែងក្នុងប្រការ ៧ ខាងក្រោម។ ត្រូវដាក់ជូនរបាយការណ៍ពីការបំពានទាំងអស់ ទៅក្រសួង ឬស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចទទួលខុសត្រូវក្នុង ការអនុវត្តន៍អនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។

ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវរៀបចំយន្តការរួមមួយ ដើម្បីឱ្យអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល បុគ្គលិកសុខាភិបាល និងសាធារណជនយល់អំពីសិទ្ធិរបស់ពួកគេ ក្នុងការរាយការណ៍អំពីការបំពានលើអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ និងផ្តល់ពីរបៀបធ្វើរបាយការណ៍ពីការបំពានអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ព្រមទាំងសិទ្ធិរាយការណ៍ជូនក្រុមប្រឹក្សាតាមដានដែលបង្កើតឡើងតាមប្រការ ៧ ខាងក្រោម។

**ប្រការ ៧.-**

ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីការចេញប្រកាសរួមនេះ ក្រសួងសុខាភិបាល ត្រូវបង្កើតក្រុមប្រឹក្សា តាមដានមួយក្នុងគោលបំណងតាមដានប្រសិទ្ធភាពនៃការអនុវត្តន៍អនុក្រឹត្យ និងប្រកាសរួមនេះ។ សមាសភាពនៃ ក្រុមប្រឹក្សាតាមដានត្រូវមានតំណាងរបស់ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយត្រូវមានប្រធានជាតំណាងរបស់ក្រសួងសុខាភិបាល។ ក្រុមប្រឹក្សាតាមដាននេះត្រូវកោះប្រជុំ (រៀងរាល់ត្រីមាស) ហើយត្រូវបំពេញតួនាទីនិងភារកិច្ចដូចខាងក្រោម ÷

១-ទទួល និងពិចារណាលើរបាយការណ៍ស្តីពីការអនុវត្តន៍អនុក្រឹត្យ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារដែលផ្ញើមកពីក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលអធិប្បាយពីរបៀបអនុវត្តន៍កាតព្វកិច្ច និងការទទួលខុសត្រូវតាមប្រការ ២ ដល់ ប្រការ ៦ នៃប្រកាសរួមនេះ។

២-ទទួល និងពិចារណាលើរបាយការណ៍ពីអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល បុគ្គលិកសុខាភិបាល និងសាធារណជន ដែលទាក់ទិននឹងដំណើរការបំពានអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។

៣- ចងក្រង និងផ្សព្វផ្សាយទាំងនៅក្នុងប្រទេស និងអន្តរជាតិនូវរបាយការណ៍រៀងរាល់ឆ្នាំស្តីពីការបំពាន និងវិធានការដែលបានអនុវត្តដើម្បីដោះស្រាយ ។

៤-ពិនិត្យលទ្ធផលការរីកចំរើនដែលសំរេចបានប្រចាំឆ្នាំ និងឧបសគ្គដែលនាយកដ្ឋាន/កម្មវិធី/មជ្ឈមណ្ឌលផ្សេងៗរបស់ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងព័ត៌មាន ជួបប្រទះដើម្បីអនុវត្តអនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ និងផ្តល់អនុសាសន៍ណែនាំពី របៀបកែលំអ។

៥-សំណើដល់រាជរដ្ឋាភិបាល អង្គការដៃគូ និងម្ចាស់ជំនួយក្នុងការស្វែងរកធនធាន និងមូលនិធិដើម្បីគាំទ្រការអនុវត្តន៍អនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។

**ប្រការ ៨.-**

ក្រសួងសាមីទាំងអស់ខាងលើត្រូវបណ្តុះបណ្តាលមន្ត្រី បុគ្គលិក ស្តីពីការអនុវត្តន៍អនុក្រឹត្យ និងប្រកាសរួមនេះ។ ក្រុមប្រឹក្សាតាមដាន ត្រូវចាត់ចែងអោយមានការផ្សព្វផ្សាយអនុក្រឹត្យ និងប្រកាសរួមនេះអោយបានទូលំទូលាយជាសាធារណៈ។

ក្រសួងពាណិជ្ជកម្ម | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ក្រសួងព័ត៌មាន | ក្រសួងសុខាភិបាល

រដ្ឋមន្ត្រី | រដ្ឋមន្ត្រី | រដ្ឋមន្ត្រី | រដ្ឋមន្ត្រី

ចម_ប្រសិទ្ធ | ស៊ុយ_សែម | ខៀវ កាញារីទ្ធ | វេជ្ជ. នុត_សុខុម

**ចម្លងជូន ÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត-ក្រុង ដើម្បីជ្រាបជាព័ត៌មាន
- គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង ដើម្បីអនុវត្ត
- គ្រប់មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ដើម្បីអនុវត្ត
- គ្រប់មន្ទីរឧស្សាហកម្មរ៉ែថាមពលខេត្ត-ក្រុង ដើម្បីអនុវត្ត
- គ្រប់មន្ទីរព័ត៌មានខេត្ត-ក្រុង ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ